ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការ
ទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
អគ្គលេខាធិការដ្ឋាន
លេខៈ ១៥៩ /០៩ អ.ល.គ.ស.ក

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៩

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សា

យោងតាមសេចក្តីសំរេចលេខ ០១/០៥ គ.ទ.ក សសរ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០០៥ ស្តីពីការជ្រើសរើសមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សា អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ក្រសួង មន្ទីរ គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ គ្រឹះស្ថានឧត្តមសិក្សាឯកជន និងសាធារណៈជនទាំងអស់ឱ្យបានជ្រាបថាៈ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ត្រូវការជ្រើសរើសមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សាដើម្បីចូលរួមក្នុងការវាយតម្លៃគុណភាពអប់រំ នៅតាមគ្រឹះស្ថានឧត្តមសិក្សា ក្នុងព្រះរាជាណាចក្រកម្ពុជា។

បេក្ខជនទាំងពីរភេទត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោមៈ

១– ត្រូវមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ

២– ត្រូវមានបទពិសោធន៍ការងារក្នុងវិស័យអប់រំឧត្តមសិក្សា យ៉ាងតិច ៥ឆ្នាំ

៣– ត្រូវមានឯកទេសស្របនឹងជំនាញនានា ដែលកំពុងបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានឧត្តមសិក្សា ក្នុងព្រះរាជាណាចក្រកម្ពុជា

៤– មានបុគ្គលិកលក្ខណៈ អត្តចរិកសមរម្យ និងមានការទទួលខុសត្រូវលើការងាររបស់ខ្លួន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោក លោកស្រី ដែលមានចំណាប់អារម្មណ៍ ក្នុងការងារនេះសូមទំនាក់ទំនង និងដាក់ពាក្យសុំចូលបម្រើការងារ នៅអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ដែលមានទីតាំងស្ថិតនៅ ជាន់ទី៤ បន្ទប់លេខ ៤២៨ អាគារទីស្តីការគណៈរដ្ឋមន្ត្រី រាល់ម៉ោងធ្វើការ ចាប់ពីថ្ងៃជូនដំណឹងរហូតដល់ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ២០០៩ ។

**ទូរស័ព្ទទំនាក់ទំនងលេខ ០២៣ ២២៤ ៦២០ , ០១២ ៧១៩ ៨៨៧ , ០១២ ៤៧៣ ៧០១**

អគ្គលេខាធិការ

បណ្ឌិតរដ្ឋ គីម សំណាង

**ចម្លងជូន**

- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រប់គ្រឹះស្ថានឧត្តមសិក្សា
- ឯកសារ-កាលប្បវត្តិ